**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :........៧៣៨៧...........ក.ប /ខ.៧

# សារលិខិតអបអរសាទរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

***សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏មហានក្ខត្តឫក្សវិសេសវិសាល និងជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុតដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសតាំងជា " **ឯកអគ្គរាជទូតសុច្ឆន្ទៈទេសចរណ៍អន្តរជាតិ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព** " **Ambassador for International Year of Sustainable Tourism and Sustainable Development Goals** " និងជ័យលាភី " **រាជធានីភ្នំពេញជា រាជធានីនៃទេសចរណ៍ និងវប្បធម៌ពិភពលោកសម្រាប់ឆ្នាំ២០១៧-២០១៨ Phnom Penh World Capital of Tourism and Culture for 2017-2018** " របស់ក្រុមប្រឹក្សាទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុប ( **European Council on Tourism and Trade-ECTT** )។

សមិទ្ធផលដ៏ធំធេងទាំងពីរខាងលើ ដែលក្រុមប្រឹក្សាភិបាលទេសចរណ៍ និងពាណិជ្ជកម្មអឺរ៉ុបបានប្រគល់ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាពេលនេះពិតជាបានកើតឡើងដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកប ដោយទស្សនវិស័យ និងបញ្ញាញាណដ៏ឈ្លាសវៃ ហើយពិតជាស័ក្តិសមបំផុតចំពោះគំរូវីរភាព និងគុណបំណាច់ដ៏ថ្លៃថ្លាក្នុងការខិតខំបំពេញការងារបម្រើប្រទេសជាតិឱ្យរីកចម្រើនលើគ្រប់វិស័យ ដែលប្រែក្លាយរាជធានីភ្នំពេញ និងតំបន់ទេសចរណ៍នានានៅកម្ពុជាឱ្យទៅជាគោលដៅទេសចរណ៍អាទិភាពក្នុងតំបន់។ ក្នុងឱកាស ដែលប្រកបដោយមោទនភាពជាតិនេះ យើងខ្ញុំសូមថ្លែងនូវការគោរពកោតសរសើរ និងដឹងគុណចំពោះ **សម្តេចតេជោ** ដែលបានដឹកនាំប្រទេសកម្ពុជាឱ្យមានកិត្យានុភាពល្បីរន្ទឺពាសពេញសកលលោក។

យើងខ្ញុំទាំងអស់គ្នា ពិតជាមានមោទនភាពជាទីបំផុត និងសូមយកឱកាសដ៏មហាប្រសើរថ្លៃថ្លានេះ បួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រសិទ្ធពរជ័យ បវរសួស្តីសិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ ជូនដល់ **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សូមបានសមប្រកបនូវសុខភាពល្អបរិបូណ៌ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំ និងអភិវឌ្ឍមាតុភូមិកម្ពុជាក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមបម្រើជាតិ និងប្រជាជនកម្ពុជាឱ្យកាន់តែរីកចម្រើនឈានឆ្ពោះទៅរកភាពរុងរឿងសំបូរសប្បាយជានិច្ចនិរន្តរ៍។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែធ្នូ គ.ស. ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**